**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ: ១៤៣៤៣ ប្រ.ក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការផ្តល់ឧវិការខ្ទាន់លើការគ្រប់គ្រង និងការប្រមូលចំណូល ពីកម្រៃសេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

| | |
|---|---|
| **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី** | **ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី** |
| **ក្រសួងមហាផ្ទៃ** | **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** |

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក
- បានឃើញអនុក្រឹត្យលេខ ១៧២ អនក្រ.បក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក
- បានឃើញសេចក្តីសម្រេចលេខ ១២សសរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ស្រុក ខណ្ឌ
- បានឃើញបទបញ្ញាលេខ ០៤ បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសអន្តរក្រសួងលេខ.០៤៣/៤២៧ប្រកចុះថ្ងៃទី.២៩ ខែ.ធ្នូ... ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតម្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# សម្រេច

**ប្រការ១ .-**

ត្រូវបានផ្តល់ថវិការង្វាន់ជូនរដ្ឋបាលថ្នាក់ក្រោមជាតិ អគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ និង មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលរបស់ រដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់ឧបត្ថម្ភជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀត ព្រមទាំងសម្រាប់ ពង្រឹងយន្តការប្រមូលចំណូល។

**ប្រការ២ .-**

អនុញ្ញាតឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ បុរេប្រទានថវិការង្វាន់ ដោយដកយកពីប្រាក់ចំណូលដែល ប្រមូលបានពីការយកកម្រៃសេវារដ្ឋបាល នៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ថវិការង្វាន់ដែលបានបុរេប្រទាននេះ ត្រូវបានអនុញ្ញាតឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗប្រើប្រាស់ សម្រាប់ការចំណាយឧបត្ថម្ភជូនមន្ត្រី និងពង្រឹងយន្តការប្រមូលចំណូល ដែលបានកំណត់នៅក្នុងប្រការ១នៃ ប្រកាសអន្តរក្រសួងនេះ។ ថវិការង្វាន់ដែលអនុញ្ញាតឱ្យបុរេប្រទាន រួមមានចំណែកថវិការង្វាន់របស់រដ្ឋបាល ថ្នាក់ក្រោមជាតិនីមួយៗ ចំណែកថវិការង្វាន់របស់អគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ និងចំណែកថវិការង្វាន់ របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្តសាមី។

**ប្រការ៣ .-**

ប្រាក់ចំណូលដែលប្រមូលបានពីកម្រៃសេវារដ្ឋបាល ត្រូវបានបែងចែកសម្រាប់បង់ចូលថវិការបស់ រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងផ្តល់ជាថវិការង្វាន់ជូនរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ អគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងមហាផ្ទៃ និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្តសាមី ផ្អែកតាមសមាមាត្រភាគរយធៀបទៅនឹង ប្រាក់ចំណូលប្រមូលបាន ដែលបានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសអន្តរក្រសួងនេះ។

**ប្រការ៤ .-**

ការប្រើប្រាស់ថវិការង្វាន់សម្រាប់ឧបត្ថម្ភលើកទឹកចិត្តមន្ត្រីរាជការ ត្រូវអនុវត្តដូចខាងក្រោម ៖

ក. ការបើកផ្តល់រង្វាន់លើកទឹកចិត្តជូនមន្ត្រីរាជការនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវអនុលោម តាមការសម្រេចរបស់ក្រុមប្រឹក្សានៃរដ្ឋបាលរបស់ខ្លួន ដោយឈរលើគោលការណ៍សមធម៌ និង ផ្អែកតាមគុណសម្បត្តិការងារ។

ខ. ការបើកផ្តល់រង្វាន់លើកទឹកចិត្តជូនមន្ត្រីរាជការរបស់អគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

គ. ការបើកផ្តល់រង្វាន់លើកទឹកចិត្តជូនមន្ត្រីរាជការរបស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

**ប្រការ៥ .–**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវគ្រោងចំណូល និងចំណាយដែលជាកម្មវត្ថុសម្រាប់ការផ្តល់ថវិការង្វាន់ នៅក្នុងគម្រោងចំណូល និងចំណាយនៃថវិកាប្រចាំឆ្នាំរបស់ខ្លួន។ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវគ្រោងឥណទានរង្វាន់ ដោយគិតបញ្ចូលរួមទាំងឥណទានសម្រាប់ការចំណាយលើថវិការង្វាន់របស់អគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្តសាមី។

រាល់ប្រតិបត្តិការនៃចំណូល និងចំណាយទាំងនេះ ត្រូវកត់ត្រាឆ្លុះបញ្ចាំងក្នុងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដូចប្រតិបត្តិការនៃចំណូល និងចំណាយដទៃទៀតរបស់ខ្លួនដែរ។ ឥណទានដែលបានគ្រោងសម្រាប់ការចំណាយលើថវិការង្វាន់នេះ ជាកម្មវត្ថុនៃការធ្វើអាណត្តិបើកប្រាក់(អាណត្តិនិយ័តកម្ម) ដើម្បីទូទាត់ជាមួយចំនួនទឹកប្រាក់ដែលបានបុរេប្រទានពីចំណូលថវិកាជាតិ។

**ប្រការ៦ .–**

រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗដែលជាថ្នាក់ថវិកា ត្រូវធ្វើសំណើសុំទូទាត់ថវិការង្វាន់សរុបប្រចាំខែ ដោយអនុវត្តតាមនីតិវិធី ដូចខាងក្រោម ÷

ក. **ផ្នែកចំណូល :** ធ្វើសលាកប័ត្រចំណូលថវិកាជាតិនូវចំនួនទឹកប្រាក់ដែលបានបុរេប្រទាន និងសំណើសុំកត់ត្រាចំណូល បញ្ជូនមកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្តសាមី ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល, តារាងសម្រង់សលាកប័ត្រចំណូលថវិកាជាតិ និងប័ណ្ណបង់ប្រាក់, តារាងគណនាថវិការង្វាន់ និងរបាយការណ៍ចំណាយថវិការង្វាន់ដែលបានអនុវត្តកន្លងមក។ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រចំណូលថវិកាជាតិ។

ខ. **ផ្នែកចំណាយ :** ធ្វើអាណត្តិបើកប្រាក់(អាណត្តិនិយ័តកម្ម) ដោយចុះចំនួនទឹកប្រាក់ស្មើនឹងចំនួនទឹកប្រាក់បុរេប្រទានដែលបានចុះក្នុងសលាកប័ត្រចំណូលថវិកាជាតិ។

**ប្រការ៧ .–**

ត្រូវបាននិរាករណ៍ប្រកាសអន្តរក្រសួងលេខ ៦៧៤៥ ប្រក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តលើការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ៨ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩ .–**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គស្នងការ អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ តទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

កន្លែងទទួល÷

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## តារាងឧបសម្ព័ន្ធ

### ភ្ជាប់នឹងប្រកាសអន្តរក្រសួងលេខ ១៤៣៤៣ប្រក ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០១៦

### ស្តីពីការផ្តល់ថវិការង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

**ក. រដ្ឋបាលរាជធានី ខេត្ត**

| ល.រ | ប្រភេទសេវា | អត្រាបង់ចូលថវិការាជធានី ខេត្ត | អត្រាបែងចែកប្រាក់រង្វាន់ | | | | |
|---|---|---|---|---|---|---|---|
| | | | រដ្ឋបាលរាជធានី ខេត្ត | រដ្ឋបាលក្រុង ស្រុក ខណ្ឌ | រដ្ឋបាលឃុំ សង្កាត់ | អគ្គនាយកដ្ឋានរដ្ឋបាល ក.មជ | មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| **១. ការងារនីត្យានុកូលកម្ម(ការបញ្ជាក់លើឯកសារថតចម្លង)** | | | | | | | |
| ១ | ការងារនីត្យានុកូលកម្ម (ការបញ្ជាក់លើឯកសារថតចម្លង) | ២៨% | ៧០% | 0% | 0% | ១% | ១% |
| **២. ការងាររដ្ឋបាល** | | | | | | | |
| ១ | ការអនុញ្ញាតឱ្យជីកឆ្លងផ្លូវ ឬ តាមបណ្តោយផ្លូវក្នុងរាជធានីភ្នំពេញ (ចំពោះការជួសជុលផ្លូវឡើងវិញឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសដូចដើម គឺជាកាតព្វកិច្ចរបស់អ្នកស្នើសុំ) | ៣៩% | ៤៤% | ១០% | ៥% | ១% | ១% |
| ២ | ការអនុញ្ញាតឱ្យជីកឆ្លងផ្លូវ ឬ តាមបណ្តោយផ្លូវក្នុងខេត្ត (ចំពោះការជួសជុលផ្លូវឡើងវិញឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសដូចដើម គឺជាកាតព្វកិច្ចរបស់អ្នកស្នើសុំ) | ២៩% | ៥៤% | ១០% | ៥% | ១% | ១% |
| ៣ | លិខិត/ប័ណ្ណឆ្លងព្រំដែន (Laissez-passer) | ២៩% | ៦៩% | 0% | 0% | ១% | ១% |
| ៤ | ការចេញលិខិតអនុញ្ញាតបំពេញអាចម៍ដីកម្មសិទ្ធិឯកជន | | | | | | |
| | - ដីក្នុងរាជធានីភ្នំពេញ ឬ ក្នុងក្រុងខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | ២៩% | ៤៩% | ១០% | ១០% | ១% | ១% |
| | - ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | ១៩% | ៥៩% | ១០% | ១០% | ១% | ១% |
| ៥ | លិខិតអនុញ្ញាតទីតាំងប៉ាណូអចល័ត (១ម៉ែត្រការ៉េ) | ២៩% | ៥៤% | ១០% | ៥% | ១% | ១% |
| **៣. ការងារវិនិយោគ** | | | | | | | |
| ១ | ការចុះបញ្ជីវិនិយោគជាគម្រោងមានលក្ខណសម្បត្តិគ្រប់គ្រាន់នៅអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត (ទុនវិនិយោគក្រោម ២លានដុល្លារអាមេរិក) | ៤៩% | ៣៩% | ៥% | ៥% | ១% | ១% |

២. រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានការិយាល័យច្រកចេញចូលតែមួយ

| ល.រ | ប្រភេទសេវា | អត្រាបង់ចូលថវិកាក្រុង ស្រុក ខណ្ឌ | អត្រាបែងចែកប្រាក់រង្វាន់ | | | | |
|---|---|---|---|---|---|---|---|
| | | | ការិយាល័យនៃមន្ទីរជំនាញ | រដ្ឋបាលក្រុង ស្រុក ខណ្ឌ | រដ្ឋបាលឃុំ សង្កាត់ | អគ្គនាយកដ្ឋានរដ្ឋបាល ក.មផ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| **១. ការងារនីត្យានុកូលកម្ម (ការបញ្ជាក់លើឯកសារថតចម្លង)** | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ២៨% | 0% | ៧0% | 0% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ១៨% | 0% | ៨0% | 0% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ៨% | 0% | ៩0% | 0% | ១% | ១% |
| **២. ការងាររដ្ឋបាល** | | | | | | | |
| ១ | ការចេញលិខិតអនុញ្ញាតបំពេញអាចម៍ដីកម្មសិទ្ធិឯកជន | | | | | | |
| | - ដីក្នុងរាជធានីភ្នំពេញ ឬ ក្នុងក្រុងខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | ២៩% | ១0% | ៤៩% | ១0% | ១% | ១% |
| | - ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | ១៩% | ១0% | ៥៩% | ១0% | ១% | ១% |
| **៣. វិស័យវប្បធម៌ និងវិចិត្រសិល្បៈ** | | | | | | | |
| **៣.១. កម្មវិធីសម្ដែងផ្សេងៗ (ក្រៅផ្លូវការ)** | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ៥% | ៣៩% | ៥% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ៥% | ៤៩% | ៥% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ៥% | ៥៩% | ៥% | ១% | ១% |
| **៣.២. ការបញ្ចាំងភាពយន្ត វីដេអូ** | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ៥% | ៣៩% | ៥% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ៥% | ៤៩% | ៥% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ៥% | ៥៩% | ៥% | ១% | ១% |

| ល.រ | ប្រភេទសេវា | អត្រាបង់ចូលថវិកាក្រុង ស្រុក ខណ្ឌ | អត្រាបែងចែកប្រាក់រង្វាន់ | | | | |
|---|---|---|---|---|---|---|---|
| | | | ការិយាល័យនៃមន្ទីរជំនាញ | រដ្ឋបាលក្រុង ស្រុក ខណ្ឌ | រដ្ឋបាលឃុំ សង្កាត់ | អគ្គនាយកដ្ឋានរដ្ឋបាល ក.មជ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ៣.៣. | អាជីវកម្មលក់ ជួលស្នាដៃភាពយន្ត វីដេអូ | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ៥% | ៣៩% | ៥% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ៥% | ៤៩% | ៥% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ៥% | ៥៩% | ៥% | ១% | ១% |
| ៣.៤. | ស្លាកសញ្ញាអាជីវកម្ម | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ៥% | ៣៩% | ៥% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ៥% | ៤៩% | ៥% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ៥% | ៥៩% | ៥% | ១% | ១% |
| ៣.៥. | អាជីវកម្មគ្រឿងបំពងសម្លេង | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ៥% | ៣៩% | ៥% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ៥% | ៤៩% | ៥% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ៥% | ៥៩% | ៥% | ១% | ១% |
| ៣.៦. | អាជីវកម្មលក់សៀវភៅ | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ៥% | ៣៩% | ៥% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ៥% | ៤៩% | ៥% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ៥% | ៥៩% | ៥% | ១% | ១% |

| ល.រ | ប្រភេទសេវា | អត្រាបង់ចូលថវិកាក្រុង ស្រុក ខណ្ឌ | អត្រាបែងចែកប្រាក់រង្វាន់ | | | | |
|---|---|---|---|---|---|---|---|
| | | | ការិយាល័យនៃមន្ទីរជំនាញ | រដ្ឋបាលក្រុង ស្រុក ខណ្ឌ | រដ្ឋបាលឃុំ សង្កាត់ | អគ្គនាយកដ្ឋានរដ្ឋបាល ក.មជ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ៣.៧. អាជីវកម្មសិល្បៈសូនរូប | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ៥% | ៣៩% | ៥% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ៥% | ៤៩% | ៥% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ៥% | ៥៩% | ៥% | ១% | ១% |
| ៣.៨. អាជីវកម្មថតរូប | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ៥% | ៣៩% | ៥% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ៥% | ៤៩% | ៥% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ៥% | ៥៩% | ៥% | ១% | ១% |
| ៣.៩. អាជីវកម្មកាត់សក់ អ៊ុតសក់ លម្អក្រចក និងសម្អាងការ (ហាង) | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ៥% | ៣៩% | ៥% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ៥% | ៤៩% | ៥% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ៥% | ៥៩% | ៥% | ១% | ១% |
| **៤. វិស័យអប់រំ យុវជន និងកីឡា** | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ៥% | ៣៩% | ៥% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ៥% | ៤៩% | ៥% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ៥% | ៥៩% | ៥% | ១% | ១% |

| ល.រ | ប្រភេទសេវា | អត្រាបង់ចូលថវិកាក្រុង ស្រុក ខណ្ឌ | អត្រាបែងចែកប្រាក់រង្វាន់ | | | | |
|---|---|---|---|---|---|---|---|
| | | | ការិយាល័យនៃមន្ទីរជំនាញ | រដ្ឋបាលក្រុង ស្រុក ខណ្ឌ | រដ្ឋបាលឃុំ សង្កាត់ | អគ្គនាយកដ្ឋានរដ្ឋបាល ក.មជ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| **៥. វិស័យទេសចរណ៍** | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ៥% | ៣៩% | ៥% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ៥% | ៤៩% | ៥% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ៥% | ៥៩% | ៥% | ១% | ១% |
| **៦. វិស័យសំណង់** | | | | | | | |
| **៦.១. លិខិតអនុញ្ញាតសាងសង់** | | | | | | | |
| ភូមិគ្រឹះ (ផ្ទៃក្រឡាកម្រាលសំណង់ ចាប់ពី ៥០០ម៉ែត្រការ៉េ ចុះក្រោម) | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ៥% | ៣៤% | ១០% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ៥% | ៤៤% | ១០% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ៥% | ៥៤% | ១០% | ១% | ១% |
| ផ្ទះល្វែង (ផ្ទៃក្រឡាកម្រាលសំណង់ ចាប់ពី ៥០០ម៉ែត្រការ៉េ ចុះក្រោម) | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ៥% | ៣៤% | ១០% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ៥% | ៤៤% | ១០% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ៥% | ៥៤% | ១០% | ១% | ១% |
| ថ្មក្រោមឈើលើ (ផ្ទៃក្រឡាកម្រាលសំណង់ ចាប់ពី ៥០០ម៉ែត្រការ៉េ ចុះក្រោម) | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ៥% | ៣៤% | ១០% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ៥% | ៤៤% | ១០% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ៥% | ៥៤% | ១០% | ១% | ១% |

| ល.រ | ប្រភេទសេវា | អត្រាបង់ចូលថវិកាក្រុង ស្រុក ខណ្ឌ | អត្រាបែងចែកប្រាក់រង្វាន់ | | | | |
|---|---|---|---|---|---|---|---|
| | | | ការិយាល័យនៃមន្ទីរជំនាញ | រដ្ឋបាលក្រុង ស្រុក ខណ្ឌ | រដ្ឋបាលឃុំ សង្កាត់ | អគ្គនាយកដ្ឋានរដ្ឋបាល ក.មជ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| **៦.២. លិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែម រុះរើ ជួសជុល** | | | | | | | |
| ភូមិគ្រឹះ (ផ្ទៃក្រឡាកម្រាលសំណង់ ចាប់ពី ៥០០ម៉ែត្រការ៉េ ចុះក្រោម) | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ៥% | ៣៤% | ១០% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ៥% | ៤៤% | ១០% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ៥% | ៥៤% | ១០% | ១% | ១% |
| ផ្ទះល្វែង (ផ្ទៃក្រឡាកម្រាលសំណង់ ចាប់ពី ៥០០ម៉ែត្រការ៉េ ចុះក្រោម) | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ៥% | ៣៤% | ១០% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ៥% | ៤៤% | ១០% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ៥% | ៥៤% | ១០% | ១% | ១% |
| ថ្មក្រោមឈើលើ (ផ្ទៃក្រឡាកម្រាលសំណង់ ចាប់ពី ៥០០ម៉ែត្រការ៉េ ចុះក្រោម) | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ៥% | ៣៤% | ១០% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ៥% | ៤៤% | ១០% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ៥% | ៥៤% | ១០% | ១% | ១% |
| **៦.៣. លិខិតអនុញ្ញាតបើកការដ្ឋាន** | | | | | | | |
| ភូមិគ្រឹះ (ផ្ទៃក្រឡាកម្រាលសំណង់ ចាប់ពី ៥០០ម៉ែត្រការ៉េ ចុះក្រោម) | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ៥% | ៣៤% | ១០% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ៥% | ៤៤% | ១០% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ៥% | ៥៤% | ១០% | ១% | ១% |

| ល.រ | ប្រភេទសេវា | អត្រាបង់ចូលថវិកាក្រុង ស្រុក ខណ្ឌ | អត្រាបែងចែកប្រាក់រង្វាន់ | | | | |
|---|---|---|---|---|---|---|---|
| | | | ការិយាល័យនៃមន្ទីរជំនាញ | រដ្ឋបាលក្រុង ស្រុក ខណ្ឌ | រដ្ឋបាលឃុំ សង្កាត់ | អគ្គនាយកដ្ឋានរដ្ឋបាល ក.មជ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ផ្ទះល្វែង (ផ្ទៃក្រឡាកម្រាលសំណង់ ចាប់ពី ៥០០ម៉ែត្រការ៉េ ចុះក្រោម) | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ១០% | ៣៤% | ៥% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ១០% | ៤៤% | ៥% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ១០% | ៥៤% | ៥% | ១% | ១% |
| ថ្មក្រោមឈើលើ (ផ្ទៃក្រឡាកម្រាលសំណង់ ចាប់ពី ៥០០ម៉ែត្រការ៉េ ចុះក្រោម) | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ១០% | ៣៤% | ៥% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ១០% | ៤៤% | ៥% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ១០% | ៥៤% | ៥% | ១% | ១% |
| **៦.៤. លិខិតបិទការដ្ឋាន ឬ វិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ** | | | | | | | |
| ភូមិគ្រឹះ (ផ្ទៃក្រឡាកម្រាលសំណង់ ចាប់ពី ៥០០ម៉ែត្រការ៉េ ចុះក្រោម) | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ១០% | ៣៤% | ៥% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ១០% | ៤៤% | ៥% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ១០% | ៥៤% | ៥% | ១% | ១% |
| ផ្ទះល្វែង (ផ្ទៃក្រឡាកម្រាលសំណង់ ចាប់ពី ៥០០ម៉ែត្រការ៉េ ចុះក្រោម) | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ១០% | ៣៤% | ៥% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ១០% | ៤៤% | ៥% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ១០% | ៥៤% | ៥% | ១% | ១% |

| ល.រ | ប្រភេទសេវា | អត្រាបង់ចូលថវិកាក្រុង ស្រុក ខណ្ឌ | អត្រាបែងចែកប្រាក់រង្វាន់ | | | | |
|---|---|---|---|---|---|---|---|
| | | | ការិយាល័យនៃមន្ទីរជំនាញ | រដ្ឋបាលក្រុង ស្រុក ខណ្ឌ | រដ្ឋបាលឃុំ សង្កាត់ | អគ្គនាយកដ្ឋានរដ្ឋបាល ក.មជ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ថ្មក្រោមឈើលើ (ផ្ទៃក្រឡាកម្រាលសំណង់ ចាប់ពី ៥០០ម៉ែត្រការ៉េ ចុះក្រោម) | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ១០% | ៣៤% | ៥% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ១០% | ៤៤% | ៥% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ១០% | ៥៤% | ៥% | ១% | ១% |
| ៦.៥. សេវាកម្ម ជួសជុល និងសាងសង់របង (របងថ្ម/បេតុង) | | | | | | | |
| លិខិតអនុញ្ញាតសាងសង់ | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ៥% | ៣៤% | ១០% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ៥% | ៤៤% | ១០% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ៥% | ៥៤% | ១០% | ១% | ១% |
| លិខិតបើកការដ្ឋាន | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ៥% | ៣៤% | ១០% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ៥% | ៤៤% | ១០% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ៥% | ៥៤% | ១០% | ១% | ១% |
| លិខិតបិទការដ្ឋាន | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ៥% | ៣៤% | ១០% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ៥% | ៤៤% | ១០% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ៥% | ៥៤% | ១០% | ១% | ១% |

| ល.រ | ប្រភេទសេវា | អត្រាបង់ចូលថវិកាក្រុង ស្រុក ខណ្ឌ | អត្រាបែងចែកប្រាក់រង្វាន់ | | | | |
|---|---|---|---|---|---|---|---|
| | | | ការិយាល័យនៃមន្ទីរជំនាញ | រដ្ឋបាលក្រុង ស្រុក ខណ្ឌ | រដ្ឋបាលឃុំ សង្កាត់ | អគ្គនាយកដ្ឋានរដ្ឋបាល ក.មផ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| **៧.ការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យ ដែលពុំទាន់ចុះបញ្ជី** | | | | | | | |
| ទំហំដី ក្រោម ១០ ០០០ម៉ែត្រការ៉េ | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ៥% | ៣៤% | ១០% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ៥% | ៤៤% | ១០% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ៥% | ៥៤% | ១០% | ១% | ១% |
| ទំហំដី ចាប់ពី ១០ ០០០ម៉ែត្រការ៉េ ដល់ក្រោម ៥០ ០០០ម៉ែត្រការ៉េ | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ៥% | ៣៤% | ១០% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ៥% | ៤៤% | ១០% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ៥% | ៥៤% | ១០% | ១% | ១% |
| ទំហំដី ចាប់ពី ៥០ ០០០ម៉ែត្រការ៉េ ឡើងទៅ | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ៥% | ៣៤% | ១០% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ៥% | ៤៤% | ១០% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ៥% | ៥៤% | ១០% | ១% | ១% |
| លំនៅដ្ឋាន (ក្រៅពីភូមិគ្រឹះ) | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ៥% | ៣៤% | ១០% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ៥% | ៤៤% | ១០% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ៥% | ៥៤% | ១០% | ១% | ១% |

| ល.រ | ប្រភេទសេវា | អត្រាបង់ចូលថវិកាក្រុង ស្រុក ខណ្ឌ | អត្រាបែងចែកប្រាក់រង្វាន់ | | | | |
|---|---|---|---|---|---|---|---|
| | | | ការិយាល័យនៃមន្ទីរជំនាញ | រដ្ឋបាលក្រុង ស្រុក ខណ្ឌ | រដ្ឋបាលឃុំ សង្កាត់ | អគ្គនាយកដ្ឋានរដ្ឋបាល ក.មផ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ភូមិគ្រឹះ | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ៥% | ៣៤% | ១០% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ៥% | ៤៤% | ១០% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ៥% | ៥៤% | ១០% | ១% | ១% |
| **៨. វិស័យឧស្សាហកម្ម និងសិប្បកម្ម និងវិស័យរ៉ែ និងថាមពល** | | | | | | | |
| ៨.១. ចុះបញ្ជីសិប្បកម្ម | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ១០% | ៣៤% | ៥% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ១០% | ៤៤% | ៥% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ១០% | ៥៤% | ៥% | ១% | ១% |
| ៨.២. ថាមពល | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ១០% | ៣៤% | ៥% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ១០% | ៤៤% | ៥% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ១០% | ៥៤% | ៥% | ១% | ១% |
| ៨.៣. សេវាកម្ម | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ១០% | ៣៤% | ៥% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ១០% | ៤៤% | ៥% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ១០% | ៥៤% | ៥% | ១% | ១% |

| ល.រ | ប្រភេទសេវា | អត្រាបង់ចូលថវិកាក្រុង ស្រុក ខណ្ឌ | អត្រាបែងចែកប្រាក់រង្វាន់ | | | | |
|---|---|---|---|---|---|---|---|
| | | | ការិយាល័យនៃមន្ទីរជំនាញ | រដ្ឋបាលក្រុង ស្រុក ខណ្ឌ | រដ្ឋបាលឃុំ សង្កាត់ | អគ្គនាយកដ្ឋានរដ្ឋបាល ក.មជ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| **៩. វិស័យពាណិជ្ជកម្ម** | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ១០% | ៣៤% | ៥% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ១០% | ៤៤% | ៥% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ១០% | ៥៤% | ៥% | ១% | ១% |
| **១០. វិស័យសុខាភិបាល** | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ១០% | ៣៤% | ៥% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ១០% | ៤៤% | ៥% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ១០% | ៥៤% | ៥% | ១% | ១% |
| **១១. វិស័យសាធារណការ និងដឹកជញ្ជូន** | | | | | | | |
| ការចុះបញ្ជីទោចក្រយានយន្ត | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ១០% | ១០% | ៧៣% | ៥% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ១០% | ១០% | ៧៣% | ៥% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ១០% | ១០% | ៧៣% | ៥% | ១% | ១% |
| **១២. វិស័យកសិកម្ម** | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ១០% | ៣៤% | ៥% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ១០% | ៤៤% | ៥% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ១០% | ៥៤% | ៥% | ១% | ១% |

គ. រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលពុំទាន់មានការិយាល័យច្រកចេញចូលតែមួយ

| ល.រ | ប្រភេទសេវា | អត្រាបង់ចូលថវិកាក្រុង ស្រុក ខណ្ឌ | អត្រាបែងចែកប្រាក់រង្វាន់ | | | | |
|---|---|---|---|---|---|---|---|
| | | | ការិយាល័យនៃមន្ទីរជំនាញ | រដ្ឋបាលក្រុង ស្រុក ខណ្ឌ | រដ្ឋបាលឃុំ សង្កាត់ | អគ្គនាយកដ្ឋានរដ្ឋបាល ក.មផ | មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| **១. ការងារនីត្យានុកូលកម្ម (ការបញ្ជាក់លើឯកសារថតចម្លង)** | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ២៨% | 0% | ៧០% | 0% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ១៨% | 0% | ៨០% | 0% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ៨% | 0% | ៩០% | 0% | ១% | ១% |
| **២. ការងាររដ្ឋបាល** | | | | | | | |
| ១ | ការចេញលិខិតអនុញ្ញាតបំពេញអាចម៍ដីកម្មសិទ្ធិឯកជន | | | | | | |
| | - ដីក្នុងរាជធានីភ្នំពេញ ឬ ក្នុងក្រុងខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | ២៩% | ៤៩% | ១០% | ១០% | ១% | ១% |
| | - ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប | ១៩% | ៥៩% | ១០% | ១០% | ១% | ១% |
| **៣. ការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យ ដែលពុំទាន់ចុះបញ្ជី** | | | | | | | |
| ដី | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ៥% | ៣៤% | ១០% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ៥% | ៤៤% | ១០% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ៥% | ៥៤% | ១០% | ១% | ១% |
| លំនៅដ្ឋាន (ក្រៅពីភូមិគ្រឹះ) | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ៥% | ៣៤% | ១០% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ៥% | ៤៤% | ១០% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ៥% | ៥៤% | ១០% | ១% | ១% |

| ល.រ | ប្រភេទសេវា | អត្រាបង់ចូលថវិកាក្រុង ស្រុក ខណ្ឌ | អត្រាបែងចែកប្រាក់រង្វាន់ | | | | |
|---|---|---|---|---|---|---|---|
| | | | ការិយាល័យនៃមន្ទីរជំនាញ | រដ្ឋបាលក្រុង ស្រុក ខណ្ឌ | រដ្ឋបាល ឃុំ សង្កាត់ | អគ្គនាយកដ្ឋានរដ្ឋបាល ក.មជ | មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ភូមិគ្រឹះ | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ៥% | ៣៤% | ១០% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ៥% | ៤៤% | ១០% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ៥% | ៥៤% | ១០% | ១% | ១% |
| **៤. វិស័យសុខាភិបាល** | | | | | | | |
| | - ខណ្ឌនៃរាជធានីភ្នំពេញ | ៤៩% | ១០% | ៣៤% | ៥% | ១% | ១% |
| | - ក្រុងទីរួមខេត្ត | ៣៩% | ១០% | ៤៤% | ៥% | ១% | ១% |
| | - ក្រុងក្រៅទីរួមខេត្ត និងស្រុក | ២៩% | ១០% | ៥៤% | ៥% | ១% | ១% |

**ឃ. រដ្ឋបាលឃុំ សង្កាត់**

| ល.រ | ប្រភេទសេវា | អត្រាបង់ចូលថវិកា ឃុំ សង្កាត់ | អត្រាបែងចែកប្រាក់រង្វាន់ | |
|---|---|---|---|---|
| | | | រដ្ឋបាល ឃុំ សង្កាត់ | មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| **១. ការចេញលិខិតបញ្ជាក់** | | | | |
| ១.១. ចំពោះឃុំ សង្កាត់ក្នុងខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ព្រះវិហារ និងខេត្តឧត្តរមានជ័យ | | | | |
| | - សង្កាត់ក្នុងក្រុង | ១០% | ៨៩% | ១% |
| | - សង្កាត់ ឬ ឃុំក្នុងស្រុក | ១០% | ៨៩% | ១% |
| ១.២. ចំពោះឃុំ សង្កាត់ក្នុងរាជធានី ខេត្ត ក្រៅពីខេត្តទាំង៥ ខាងលើ | | | | |
| | - សង្កាត់ក្នុងខណ្ឌ | ៣០% | ៦៩% | ១% |
| | - សង្កាត់ក្នុងក្រុង | ២០% | ៧៩% | ១% |
| | - សង្កាត់ ឬ ឃុំក្នុងស្រុក | ១០% | ៨៩% | ១% |